ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ទី ៣ លេខ ១៧-១៨ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I . ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១៣-៥-១៩៩៥ – អនុក្រឹត្យលេខ ៤១ អនក្រ. បក ស្តីពីការចំណាយឥតព្រាងទុក ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់របស់ក្រសួងការពារជាតិ ៦៧២
១៧-៥-១៩៩៥ – អនុក្រឹត្យលេខ ៤២ អនក្រ. បក ស្តីពីការបង្កើតគណៈកម្មាធិការ សំរុះសំរួលទំនាស់ពាក់ព័ន្ធ និង កិច្ចការមុខងារសាធារណៈ ៦៧៤
១៧-៥-១៩៩៥ – អនុក្រឹត្យលេខ ៤៣ អនក្រ ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និង ផ្សព្វផ្សាយ ៦៧៥
១៦-៥-១៩៩៥ – អនុក្រឹត្យលេខ ៥៣ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៧៧
១៩-៥-១៩៩៥ – អនុក្រឹត្យលេខ ៥៥ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧៨
១៩-៥-១៩៩៥ – អនុក្រឹត្យលេខ ៥៦ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧៩
១៩-៥-១៩៩៥ – អនុក្រឹត្យលេខ ៥៧ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៨១
១៩-៥-១៩៩៥ – អនុក្រឹត្យលេខ ៥៨ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៨២
១៩-៥-១៩៩៥ – អនុក្រឹត្យលេខ ៥៩ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៨៤
១៩-៥-១៩៩៥ – អនុក្រឹត្យលេខ ៦០ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៨៥
២០-៥-១៩៩៥ – អនុក្រឹត្យលេខ ៦១ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៨៦
២២-៥-១៩៩៥ – អនុក្រឹត្យលេខ ៦២ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៨៧
២៣-៥-១៩៩៥ – អនុក្រឹត្យលេខ ៦៣ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៨៨

២-សេចក្តីជូនដំណឹង

១០-៥-១៩៩៥ – សេចក្តីជូនដំណឹងលេខ ៣១ សជណ ស្តីពីសំណើធ្វើកិច្ចសហការអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលជាមួយមូល

និធិរូបិយវត្ថុអន្តរជាតិ "IMF" ដោយផ្តល់នូវទិន្នន័យ និង តួលេខមួយចំនួន ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៦៨៩

II-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១០-៥-១៩៩៥	- សេចក្តីប្រកាសលេខ ១០២ ប្រក.សហវ.ថ ស្តីពីការបង្វែរឥណទាន	៦៩២
១៦-៥-១៩៩៥	- សេចក្តីប្រកាសលេខ ១០៨ ប្រក.សហវ.ហ ស្តីពីការបង្វែរថវិកាដែលក្រុមហ៊ុនអាកាសចរកម្ពុជាជំពាក់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាដល់ដំណាច់ខែ មករា ឆ្នាំ ១៩៩៤ ចំនួន ៥៩០.១៨៥,៣៣ ដុល្លារអាមេរិក និង ១.៥៤២.៩៦៦.១៦១៖០០	៦៩៤
២០-៥-១៩៩៥	- សេចក្តីប្រកាសលេខ ១១២ ប្រក.សហវថ ស្តីអំពីការបង្វែរឥណទាន	៦៩៦
២២-៥-១៩៩៥	- សេចក្តីសំរេចលេខ ០០៩ សសរ.សហវ.ខ ស្តីពីការដាកពិន័យ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការអំពីករណីរត់ពន្ធល្មើសច្បាប់របស់ក្រុមហ៊ុន គីម ហាប់ និង ក្រុមហ៊ុន VASAN SHIPPING & TRANDING PTE, LTD ម្ចាស់នាវា GENA	៦៩៨

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១២-៥-១៩៩៤	- ប្រកាសលេខ ៣៥៧ ឧក.ប្រក អនុញ្ញាតអោយអ្នកស្រី តែង ឡែន បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣៧ សេះ	៧០០

១២-៥-១៩៩៥ – ប្រកាសលេខ ៣៥៨ ផក.ប្រក អនុញ្ញាតអោយ អ្នកស្រី
គង់ សាយហួយ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីន
កិនស្រូវ កំលាំង ៤០ សេះ ៧០០
១២-៥-១៩៩៥ – ប្រកាសលេខ ៣៥៩ ផក.ប្រកអនុញ្ញាតអោយ លោក
ឈឹម សាក់ ជនជាតិ ខ្មែរ បើកដំណើរការរោងម៉ាស៊ីន
កិនស្រូវ កំលាំង ១២០ សេះ ៧០១
១២-៥-១៩៩៥ – ប្រកាសលេខ ៣៦០ ផក.ប្រក អនុញ្ញាតអោយ លោក
ញ៉ុក វុទ្ធី ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិន
ស្រូវ កំលាំង ៨០ សេះ ៧០១
១២-៥-១៩៩៥ – ប្រកាសលេខ ៣៦១ ផក.ប្រក អនុញ្ញាតអោយ លោក
លៀម រាស ជនជាតិ ខ្មែរ បើកដំណើរការរោងម៉ាស៊ីន
កិនស្រូវ កំលាំង ៣១ សេះ ៧០២
១២-៥-១៩៩៥ – ប្រកាសលេខ ៣៦២ ផក.ប្រក អនុញ្ញាតអោយ លោក
ទិត ម៉ុង ជនជាតិ ខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិន
ស្រូវ កំលាំង ១៦ សេះ ៧០៣
១២-៥-១៩៩៥ – ប្រកាសលេខ ៣៦៣ ផក.ប្រក អនុញ្ញាតអោយ លោក
ជ្រា ប៉េង ជនជាតិ ខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិន
ស្រូវ កំលាំង ១៦ សេះ ៧០៣
១២-៥-១៩៩៥ – ប្រកាសលេខ ៣៦៤ ផក.ប្រក អនុញ្ញាតអោយ អ្នកស្រី
យុន តៀវ ជនជាតិ ខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិន
ស្រូវ កំលាំង ២១ សេះ ៧០៤
១២-៥-១៩៩៥ – ប្រកាសលេខ ៣៦៥ ផក.ប្រក អនុញ្ញាតអោយ លោក
ឈាង ហ៊ន ជនជាតិ ខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិន
ស្រូវ កំលាំង ១៦ សេះ ៧០៥
១២-៥-១៩៩៥ – ប្រកាសលេខ ៣៦៦ ផក.ប្រក អនុញ្ញាតអោយ លោក

	ណុប ផែម ជនជាតិ ខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ	៧០៥
១២-៥-១៩៥៥	– ប្រកាសលេខ ៣៦៧ ផក.ប្រក អនុញ្ញាតអោយ លោក ឈាង គួ ជនជាតិខ្មែរ បន្តដំណើរការផលិតកម្មទឹកកកដើម	៧០៥
១២-៥-១៩៥៥	– ប្រកាសលេខ ៣៦៨ ផក.ប្រក អនុញ្ញាតអោយ លោក ហ៊ី ពួយ ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកកគ្រាប់	៧០៦
១២-៥-១៩៥៥	– ប្រកាសលេខ ៣៦៩ ផក.ប្រក អនុញ្ញាតអោយ លោក ភោគ ហៀង ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកកដើម	៧០៦
១២-៥-១៩៥៥	– ប្រកាសលេខ ៣៧០ ផក.ប្រក អនុញ្ញាតអោយ លោក ស៊ុំ សេង ជនជាតិ ខ្មែរ បើកដំណើរការផលិតកម្មទឹកកកដើម	៧០៧
១២-៥-១៩៥៥	– ប្រកាសលេខ ៣៧១ ផក.ប្រក អនុញ្ញាតអោយ លោក អ៊ិក ម៉ាប់ ជនជាតិ ខ្មែរ បើកដំណើរការរោងជាងក្រឡឹងដែក	៧០៧
១៧-៥-១៩៥៥	– ប្រកាសលេខ ៣៧៨ ផក.ប្រក អនុញ្ញាតអោយ លោក ម៉ា សុជាតិ ជនជាតិ ខ្មែរ បើកដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ «ម៉ូឌែន»	៧០៧
១៩-៥-១៩៥៥	– ប្រកាសលេខ ៣៨០ ផក.ប្រក អនុញ្ញាតអោយ លោក កៃ សឿន ជនជាតិ ខ្មែរ បន្តដំណើការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ	៧០៨
១៩-៥-១៩៥៥	– ប្រកាសលេខ ៣៨១ ផក.ប្រក អនុញ្ញាតអោយ អ្នកស្រី សៀង សុង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ	៧០៨
១៩-៥-១៩៥៥	– ប្រកាសលេខ ៣៨២ ផក.ប្រក អនុញ្ញាតអោយ លោក ផូ កុល ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២០ សេះ	៧០៩
១៩-៥-១៩៥៥	– ប្រកាសលេខ ៣៨៣ ផក.ប្រក អនុញ្ញាតអោយ លោក	

	ស សៀន ជនជាតិខ្មែរ បើកដំណើរការឧស្សាកម្មតូច ផលិតទឹកកកដើម	៧០៩
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៨៤ ផក.ប្រក អនុញ្ញាតអោយ លោក សុខ លាវ ជនជាតិ ខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ	៧១០
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៨៥ ផក.ប្រក អនុញ្ញាតអោយ អ្នកស្រី ប៊ុន អ៊ី ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើម	៧១០
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៨៦ ផក.ប្រក អនុញ្ញាតអោយ លោក ភិន ប៉ុស ជាប្រធានរោងម៉ាស៊ីនស្រូវកំលាំង ៦៥ សេះ ផ្ទេរភារកិច្ចគ្រប់គ្រងជូនអ្នកស្រី ចូត គីមឡាង	៧១១
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៨៧ ផក.ប្រក អនុញ្ញាតអោយ អ្នកស្រី ឈឹម ប៊ុនណា ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	៧១១
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៨៨ ផក.ប្រក អនុញ្ញាតអោយ អ្នកស្រី ហ៊ិន សារិន ជន ជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	៧១២
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៨៩ ផក.ប្រក អនុញ្ញាតអោយ លោក កុល សុធា ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មកែច្នៃតែយីហោ «ចាន់-ប៊ិន» និង យីហោ «ហាក់-ហេង»	៧១២
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៩០ ផក.ប្រក អនុញ្ញាតអោយរោងម៉ាស៊ីកិនស្រូវដែលមានលោក ធី ខៃលៀង ជនជាតិខ្មែរ បន្តដំណើរការផលិតកម្មដោយ ប្រើម៉ាស៊ីនកំលាំង ៨០ សេះ	៧១៣
១៩-៥-១៩៩៥	– ប្រកាសលេខ ៣៩១ ផក.ប្រក អនុញ្ញាតអោយ លោក ជាង គីមម៉ាប់ ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្ម	

ក្លូចផលិត ទឹកកកដើម ៧១៣

៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១២–៥–១៩៩៥ – ប្រកាសលេខ ១០៦/៩៥ ពម.ប្រក អនុញ្ញាតអោយ លោក ត្រឹង ប៊ុន បើក អាជីវកម្មរោងពុម្ពឈ្មោះ «តង់ទៀង» ៧១៤
១៣–៥–១៩៩៥ – ប្រកាសលេខ ១០៧/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែតឈ្មោះ «CAMBODIA TODAY» ចេញផ្សាយជាភាសាអង់គ្លេស ៧១៥
១៤–៥–១៩៩៥ – ប្រកាសលេខ ១០៨ ពម.ប្រក លុបឈ្មោះមន្ត្រីរាជការចំនួន ៣ នាក់ ចេញក្របខ័ណ្ឌក្រសួង ៧១៦

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

១៣–៥–១៩៩៥ – ប្រកាសលេខ ៣៩២ ប្រក.សក ស្តីពីការបង្កើតគណៈកម្មាធិការ សំរបសំរួល គំរោងការស្ពាន (Project Coordinating Committee) ក្នុងក្របខ័ណ្ឌ ជំនួយឥតសំណងរបស់រដ្ឋាភិបាលអូស្ត្រាលីជូនដល់ រាជរដ្ឋាភិបាលកម្ពុជា ៧១៨

៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

ប្រកាស

០៩–៥–១៩៩៥ – ប្រកាសលេខ ០១៦ កទច.ប្រ ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះ មន្ត្រីថ្នាក់អនុប្រធានមន្ទីរ នៃមន្ទីរទេសចរណ៍ក្រុងកែប ៧២០

៦-ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

១០–៥–១៩៩៥ – ប្រកាសលេខ ១០៤ ប្រក.វវស.បុ ស្តីពីការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស ៧២១

៧-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៦–៥–១៩៩៥ – ប្រកាសលេខ ៤៤៥ អយក.ប្រក ស្តីពីការសុំបើកសាលាបឋមសិក្សាកំពតក្រុង ៧២២

៨-ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

១០–៥–១៩៩៥ – ប្រកាសលេខ ៨៦១ ប្រក.បស្ថ ស្តីពីការទទួលស្គាល់ និង ធ្វើកម្មសិក្សាជូន មន្ត្រីរាជការ ៧២៤

១៦–៥–១៩៩៥ – ប្រកាសលេខ ៨៨៨ ប្រក.បស្ថ ស្តីពីការទទួលស្គាល់មន្ត្រីរាជការ ៧២៦

១៧–៥–១៩៩៥ – ប្រកាសលេខ ៨៩៨ បស្ថ.ចត ស្តីពីការទទួលស្គាល់ និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ៧២៧

១៩–៩–១៩៩៥ – ប្រកាសលេខ ៩១៤ ប្រក.បស្ថ ស្តីពីការតែងតាំងមន្ត្រីរាជការ ៧២៨

៩-ទីស្តីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

០៩-៥-១៩៩៥ – ប្រកាសលេខ ៩១/៩៥ កធស.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៧២៩

– ប្រកាសលេខ ៩២/៩៥ កធស.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៣០

១០-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

២២-៥-១៩៩៥ – ប្រកាសលេខ ១៩៩ ពណបលប្រក ផ្ទេរភារកិច្ច និង ចាត់តាំង លោក ពួន ម៉ារ៉េត បច្ចុប្បន្នមន្ត្រីគណៈកម្មាធិការត្រួតពិនិត្យ អោយទទួលជាមន្ត្រី ពតិមានរបស់ក្រសួងពាណិជ្ជកម្ម ៧៣៣

១១-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

១២-៥-១៩៩៥ – សេចក្តីសំរេចលេខ ២៩៤ សសរ.មស.ក្រខ ស្តីពីការបែងចែក និស្សិតចំនួន ៤៩ នាក់ ដែលទើបបញ្ចប់ការសិក្សាក្រៅប្រទេស ៧៣៤

I .ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤១ អនក្រ.បក

ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈ
ចាំបាច់ និង បន្ទាន់ របស់ក្រសួងការពារជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : កំណត់អោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោះស្រាយថវិកាសំរាប់ការចំណាយក្រៅគំរោងផែនការ ដែលចាត់ទុកជាការប្រញាប់របស់ក្រសួងការពារជាតិ តាមអាទិភាព ដែលមានជាលំដាប់លំដោយដូចខាងក្រោម ÷

១–ការចំណាយមានចំនួនទឹកប្រាក់ : ៨.៤៤៤.០០០.០០០រ០០ (ស្មើនឹង ៣.៣៧៧.៦០០$) សំរាប់បំពេញកង្វះការចំណាយឆ្នាំ ១៩៩៤ របស់អគ្គសេនាធិការ ។

២–ការចំណាយមានចំនួនទឹកប្រាក់ : ៧៩២.០០០$ ដុល្លារអាមេរិក សំរាប់ទូទាត់ថ្លៃទំនិញពិសេស គ្រាប់បួម ។

៣-ការចំណាយមានចំនួនទឹកប្រាក់ : ៦១៩.៨០០$ ដុល្លារអាមេរិក សំរាប់ជួសជុលអគ្គបញ្ជាការដ្ឋាន ។

៤-ការចំណាយមានចំនួនទឹកប្រាក់ : ១.៥៩៩.៥០០$ ដុល្លារអាមេរិក សំរាប់ទូទាត់ជំហានទី ១ ថ្លៃទិញយន្តហោះ L39 ចំនួន ៧ គ្រឿង និង ជួសជុលយន្តហោះ MIG 21 ចំនួន ៨ គ្រឿង ។

៥-ការចំណាយមានចំនួនទឹកប្រាក់ : ៤២៤.៦៣៣,៥០$ ដុល្លារអាមេរិក សំរាប់ទូទាត់ជំហានទី ២ និង ទី ៣ ថ្លៃទិញយន្តហោះ Y-12 ចំនួន ២ គ្រឿង ។

៦-ការចំណាយមានចំនួនទឹកប្រាក់ : ១.៤៦០.០០០$ ដុល្លារអាមេរិក សំរាប់ទិញគ្រឿងឧបករណ៍ពេទ្យបំពាក់អោយអាគារបំរើអោយការវះកាត់ នៅមន្ទីរពេទ្យព្រះកេតុមាលា ។

៧-ការចំណាយមានចំនួនទឹកប្រាក់ : ៦៧.៧៨៥$ ដុល្លារអាមេរិក សំរាប់ទិញសំភារៈប្រើប្រាស់ នៅអគ្គបញ្ជាការដ្ឋាន ។

៨-ការចំណាយទឹកប្រាក់ចំនួន : ១.០០០.០០០$ ដុល្លារអាមេរិក សំរាប់សងលោកឧញ៉ា ថេង ប៊ុនម៉ា ។

សរុបទឹកប្រាក់ទាំងអស់ចំនួន : ៩.៣៤១.៣១៨,៥០$ ដុល្លារអាមេរិក (ប្រាំបួនលានបីរយសែសិបមួយពាន់ បីរយដប់ប្រាំបីដុល្លារអាមេរិក និង ហាសិបសេន) ។

មាត្រា ២: ចំពោះថវិកាចំណាយរបស់ក្រសួងការពារជាតិ ក្រៅពីការកំណត់ក្នុងមាត្រាខាងលើ រាជរដ្ឋាភិបាលនឹងកំណត់អោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោះស្រាយជាក្រោយ។

មាត្រា ៣: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលការអនុវត្តន៍តាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤២ អនក្រ.បក

ស្តីពីការបង្កើតគណៈកម្មាធិការសំរុះសំរួល

ទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថា :

គណៈកម្មាធិការសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ។

មាត្រា ២ : សមាសភាពគណៈកម្មាធិការនេះរួមមាន :

១-រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ	ប្រធាន
២-សហអនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៣-តំណាងក្រសួងមហាផ្ទៃ	សមាជិក
៤-តំណាងក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន	សមាជិក
៥-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៦-តំណាងក្រសួងអប់រំយុវជន និង កីឡា	សមាជិក
៧-មន្ត្រីនៃរដ្ឋលេខាធិការដ្ឋានមុខងារសារណៈ ០១ រូប	លេខាធិការ

មាត្រា ៣ : គណៈកម្មាធិការនេះ មានភារកិច្ចសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការដូចជា ត្រួតពិនិត្យកិច្ចសន្យាទាំងឡាយក្នុងផែនការនៃការបណ្តុះបណ្តាល ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការឡើងឋានន្តរសក្តិ ឬ ការដាក់វិន័យមន្ត្រីរាជការ ការផ្លាស់ប្តូរការផ្តល់ប្រាក់បំណាច់ផ្សេង ៗ ។ល។

មាត្រា ៤ : គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញតំណាងស្ថាប័នដែលមានការពាក់ព័ន្ធ និង សាមីខ្លួន មកបំភ្លឺក្នុងករណីចាំបាច់ ។

មាត្រា ៥ : ការប្រព្រឹត្តិរបស់គណៈកម្មាធិការនេះ អាស្រ័យដោយប្រធានគណៈកម្មាធិការជាអ្នកកំណត់ណែនាំ ។ គណៈកម្មាធិការនេះ មានទីតាំងនៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម អស់លោកក្នុងមាត្រា ២ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៣ អនក្រ.បក

ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកទេស
សេដ្ឋកិច្ច និង ផ្សព្វផ្សាយ

* * *

រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតនាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និង ផ្សព្វផ្សាយ ស្ថិតនៅក្រោមការគ្រប់គ្រង និង ដឹកនាំផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : នាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និង ផ្សព្វផ្សាយ មានភារកិច្ចសំខាន់ ៗ ដូចតទៅ ÷

- ស្រាវជ្រាវ និង ស្វែងយល់ពីបញ្ហាលំបាក និង តម្រូវការរបស់សហគមន៍ និង កសិករក្នុងកិច្ចអភិវឌ្ឍន៍ ។
- រៀបចកសាងគំរោងកម្មវិធីបំពាក់បំប៉នមុខជំនាញ និងប្រព័ន្ធឃោសនាអប់រំផ្សព្វផ្សាយបច្ចេកទេសលើគ្រប់ផ្នែកក្នុងវិស័យកសិកម្ម ។
- សិក្សាស្រាវជ្រាវរកគំនាស់សេដ្ឋកិច្ចកសិកម្ម និង វិះរកយុទ្ធវិធីផ្សព្វផ្សាយដើម្បីលើកទឹកចិត្តដល់មូលដ្ឋាន និង ប្រជាកសិករឈានទៅអភិវឌ្ឍន៍លើគ្រប់ផ្នែកក្នុងវិស័យកសិកម្ម។
- សិក្សាស្រាវជ្រាវ ប្រមូលផ្ដុំឯកសារបច្ចេកទេសកសិកម្មសហការជាមួយអង្គភាពជំនាញនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំអត្ថបទចងក្រងជាទស្សនាវដ្ដី ព្រឹត្តិប័ត្រ សាលាកប័ត្រ គំនូររូបភាព រឿងនិទានខ្លី ។ ខ្សែភាពយន្តកាសែ្សត វីដេអូ ។ល។ បំរើអោយការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មលើគ្រប់រូបភាព ។
- កសាងកម្មវិធីបំពាក់បំប៉នដល់ប្រជាកសិករ ដើម្បីលើកកំពស់ការយល់ដឹងខាងបច្ចេកទេសកសិកម្មសមស្របទៅតាមលក្ខណៈភូមិសាស្ត្ររបស់មូលដ្ឋាន ដោយសហការជាមួយអង្គភាពជំនាញនៅមូលដ្ឋាន ក្នុងការធ្វើបង្ហាញ និង ការអនុវត្តន៍ជាក់ស្ដែង ។

- រៀបចំការគ្រប់គ្រង និង ប្រើប្រាស់ឥណទានកសិកម្មនៅជនបទដើម្បីជំរុញផលិកម្មកសិកម្មនៅក្នុងសហគមន៍កសិករ ។
- ត្រួតពិនិត្យការអនុវត្តន៍ សន្និដ្ឋានវាយតំលៃអំពីលទ្ធផលការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មក្នុងក្របខ័ណ្ឌទូទាំងប្រទេស ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៣ : នាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និង ផ្សព្វផ្សាយ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការ ។

មាត្រា ៤ : ការបង្កើត រំសាយ និង រៀបចំតួនាទីភារៈកិច្ចការិយាល័យរបស់នាយកដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ស្ថាប័នមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារៈកិច្ចរៀង ៗ ខ្លួន ។

មាត្រា ៦ : អនុក្រឹត្យនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៣ អនក្រ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- យោងតាមសំណូមពរការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងជាក្រុមជំនួយការផ្ទាល់របស់នាយកខុទ្ទកាល័យសម្ដេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា នូវឥស្សរជនដូចមានរាយនាមខាងក្រោម ÷

១- លោក **គង់ ទិបុល**

២- លោក **គង ចំនួន**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដែលមានរាយនាមក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ដលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៥ អនក្រ.គត

ស្ដីពីការផ្ដល់មេដាយស្ថាបនា

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលស្ដីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ

- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះសប្បុរសជនដែលបានឧបត្ថម្ភប្រាក់ជួយកសាងសួនច្បារ កែលំអសោភ័ណភាពរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម :

១-លោក PAT BREWER and THE BREWER NRD CO LTD បានឧបត្ថម្ភប្រាក់ ១៥.៥០០ ដុល្លារអាមេរិក កសាងសួនច្បារមុខព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង ។

២-លោក **គុក អាន** ប្រធានក្រុមហ៊ុនអានគូ បានឧបត្ថម្ភចង្កៀងចំនួន ១០ មានតំលៃ ១៣.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយបានទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជន ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងរាជធានីភ្នំពេញ លើវិស័យអប់រំ ដូចមានរាយនាមខាង៖

ក-<u>មេដាយស្ថាបនាជាតិថ្នាក់លេខ ១</u> :

១-បណ្ឌិត **សៃមិងយូ** (TSAIMINGYU) ជនជាតិជប៉ុន ជួយអនុវិទ្យាល័យទឹកល្អក់ អស់ទឹកប្រាក់ ១០៥.១៣០ ដុល្លារអាមេរិក ។

២-លោក **តាំង ពិន** ផ្ទះលេខ ២៩ អឺ០ ផ្លូវលេខ ១២៨ សង្កាត់ផ្សារថ្មីទី ២ ជួយអនុវិទ្យាល័យទឹកល្អក់ អស់ទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក ។

៣-លោក **ពិន ឆាំង** ប្រធានក្រុមហ៊ុនថៃត្បូងប៉ៃលិន ជួយអនុវិទ្យាល័យទឹកល្អក់ អស់ទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក ។

៤-អង្គការកុមារកម្ពុជា ជួយសាលាបឋមសិក្សាស្ទឹងមានជ័យ អស់ទឹកប្រាក់ ៣៣.៧៨៨ ដុល្លារអាមេរិក ។

៥-លោកស្រី **នីអេកូ អូសាណៃ** (NIEKO OSANAI) ជនជាតិជប៉ុន ជួយសាលាមតេយ្យជ្រោយចង្វារ អស់ទឹកប្រាក់ ២៧.៥៤១ ដុល្លារអាមេរិក ។

៦-អង្គការក្រុមកំលាំងយុវជនជប៉ុន (J.H.P) ជួយសាលាបឋមសិក្សាគោកបញ្ជន់ អស់ទឹកប្រាក់ ២៥.៩២៩ ដុល្លារអាមេរិក ។

ខ-<u>មេដាយស្ថាបនាជាតិថ្នាក់លេខ ២</u> :

១-ក្រុមហ៊ុនសណ្ឋាគារអភិវឌ្ឍន៍ទីក្រុង ជួយធ្វើរបងអនុវិទ្យាល័យបឹងកេងកង អស់ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក ។

គ-<u>មេដាយស្ថាបនាជាតិថ្នាក់លេខ ៣</u> :

១–ព្រះ **តេជគុណ ជួនយ៉េន** ចៅអធិការវត្តខ្នុរ បានជួយសាងសង់អាគារសិក្សានៅវត្តខ្នុរ អស់ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក ។

២–លោក **មាក់ សេខ** ជួយសាងសង់អាគារសិក្សានៅវត្តខ្នុរ អស់ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក ។

៣–លោកតា **ឡុង ហ៊ុន** ជួយសាងសង់អាគារសិក្សានៅវត្តខ្នុរ អស់ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក ។

៤–អ្នកស្រី **ឃ្លិច ឃីម** ជួយសាងសង់អាគារសិក្សានៅវត្តខ្នុរ អស់ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក ។

៥–ព្រះតេជគុណ **ស្រី ធីម** ចៅអធិការវត្តនិរោធវង្ស ជួយជួសជុលអាគារសិក្សានៅវិទ្យាល័យច្បារអំពៅ អស់ទឹកប្រាក់ ១.១៣០ ដុល្លារអាមេរិក ។

៦–លោក **ទ្រី ហេខ** ជួយជួសជុលវិទ្យាល័យច្បារអំពៅ អស់ទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះ

មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ប្រគេនចំពោះ ព្រះតេជគុណ **ណយ ច្រឹក** ចន្ទប្បជោតោ ព្រះវិន័យធរគណៈសង្ឃស្រុកពញាឮ ដែលមានស្នាព្រះហស្តធំធេងក្នុង ការចូលរួមកសាងជាតិ និង សាសនា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សាលាក្រុងភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះអង្គការអន្តរជាតិចំនួន ០៣ ដែលបានធ្វើអំណោយជាថវិកា ដើម្បីឧបត្ថម្ភដល់វិស័យអប់រំ សិក្សាធិការរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោមនេះ :

១-អង្គការជំនួយ សូតូស៊ូ ជប៉ុន (JSRC) បានឧបត្ថម្ភដល់វគ្គបំពាក់បំប៉នមុខវិជ្ជាកាត់ដេរ ជូនបុគ្គលិកសិក្សាក្នុងរាជធានីចំនួន ៣៦ នាក់ នៅមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាព កម្ពុជា ជប៉ុន ដោយបានចំណាយថវិកាអស់ទឹកប្រាក់ ១៨.៣០០ ដុល្លារអាមេរិក ។

២-វត្តស៊ិនហ្ស៊ី (SHORINJI TEMPLE) នៅប្រទេសជប៉ុនជួយសាងសង់សាលាបឋមសិក្សាចំរើនរដ្ឋ សង្កាត់ ស្ទាយប៉ាក ខ័ណ្ឌឬស្សីកែវ អស់ទឹកប្រាក់ ២៥.០០០ ដុល្លារអាមេរិក ។

៣-អង្គការក្រុមកំលាំងយុវជនជប៉ុន (JHP) ជួយសាងសង់សាលាបឋមសិក្សាចាក់អង្រែក្រោមិត ខ័ណ្ឌមានជ័យ អស់ទឹកប្រាក់ ២៣.៥៤៨ ដុល្លារអាមេរិក។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៩ អនក្រ.តត

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និងបណ្ណស្ថាបនាជាតិ ។
- តាមសំណើរបស់អភិបាលខេត្តតាកែវ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះ លោកយាយ **ឌី ម៉ុក** ដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគថវិកាផ្ទាល់ខ្លួនជួយកសាងព្រះវិហារសាលាធម្មសភា សាលារៀនស្រះទឹក ម៉ាស៊ីនភ្លើង មីក្រូ ភ្លេងពិណពាទ្យមួយវង់ និង ព្រះពុទ្ធបដិមា ០៣ ព្រះអង្គក្នុងវត្ត ព្រៃផ្គាវ និង វត្តព្រៃផ្ទេរ ឃុំនោម ស្រុកទ្រាំង ខេត្តតាកែវ គិតជាទឹកប្រាក់សរុបស្មើនឹង ២០.៥៤២ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦០ អនក្រ.តត

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់អភិបាលខេត្តតាកែវ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ជូនចំពោះលោកតា ហ៊ុន នាង ដែលមានសទ្ធាជ្រះថ្លាជួយឧបត្ថម្ភនូវម៉ាស៊ីនភ្លើងចំនួន ០៤ គ្រឿង ដល់វត្តព្រៃជួរ វត្តអង្គជុំមានលក្ខណ៍ វត្តអង្គត្នោត វត្តអង្គតាសោម និង គសាងរបងវត្តអង្គតាសោម ក្នុងស្រុកត្រាំកក់ គិតជាទឹកប្រាក់សរុប : ៦.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦១ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីពីររូប :

- លោក **ម៉ៅ ម៊ុនរិន** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- លោក **ហេង ហាក់** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

មាត្រា ២ : ត្រូវបានតែងតាំងមន្ត្រីពីររូប :

- លោក **អៅ គីមឈួន** ជាទីប្រឹក្សាឯកឧត្តម **ប្ញ ស៊ុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- លោក **តោ សៀត** ជាទីប្រឹក្សាឯកឧត្តម **ប្ញ ស៊ុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

មាត្រា ៣ : ត្រូវបានតែងតាំងមន្ត្រីបីរូប :

- លោក **គួច លន** ជាជំនួយការឯកឧត្តម **ប្ញ ស៊ុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- លោក **ស្មួស អង្គារ** ជាជំនួយការឯកឧត្តម **ប្ញ ស៊ុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- លោក **ឌិន ទ៉ាន់ដេន** ជាជំនួយការឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង និង ប្រធានស្ថាប័នពាក់ព័ន្ធ និង អស់លោកដែលមានឈ្មោះក្នុងមាត្រា ១ មាត្រា ២ មាត្រា ៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦២ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំង :

–លោកជំទាវ **កែត ប៊ុនសួក**	ជាទីប្រឹក្សាអមស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប៉ូវ៉ាស៊ីនតោន
–លោក **មាស គីមហេង**	ជាទីប្រឹក្សាអមស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប៉ូវ៉ាស៊ីនតោន ទទួលបន្ទុកការងារនយោបាយ ។

-លោក **ម៉ៅ ចន្ទសំណាំ** ជាទីប្រឹក្សាអមស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំ ប្ញូវ៉ាស៊ីនតោន ទទួលបន្ទុកសហប្រតិបត្តិការផ្នែក សេដ្ឋកិច្ច ពាណិជ្ជកម្ម និង ទេសចរណ៍ ។

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ មុខងារសាធារណៈ និង សាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាម អនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦៣ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃ ទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ : ត្រូវបានតែងតាំងមន្ត្រីប្អូនរូប

-លោក **ហែម សារ៉ុន** ជាជំនួយការឯកឧត្តម **គៀង វ៉ាង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

-លោក **សួន ឆាសនា** ជាជំនួយការឯកឧត្តម **គៀង វ៉ាង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

-លោក **ខ្មៅ សំឡុត** ជាជំនួយការឯកឧត្តម **គៀង វ៉ាង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

-លោក **រស់ សំរុល** ជាជំនួយការឯកឧត្តម **គៀង វ៉ាង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង និង ប្រធានស្ថាប័នពាក់ព័ន្ធ និង អស់លោកមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្ត តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២-សេចក្តីជូនដំណឹង

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥

សេចក្តីជូនដំណឹង លេខ: ៣១ សជណ

* * *

កម្មវត្ថុ : សំណើធ្វើកិច្ចសហការអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល ជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ «IMF» ដោយផ្តល់នូវទិន្នន័យ និង តួលេខមួយចំនួន ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

: កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ IMF ។

ជូនភ្ជាប់ : តារាងឧបសម្ព័ន្ធទី ១ និង ទី ២ ចំនួន ០១ ច្បាប់ ។

តាមន័យដូចមានចែងក្នុងកម្មវត្ថុ យោង និង ជូនភ្ជាប់ខាងលើ ដើម្បីឈានទៅធ្វើកិច្ចសហការអនុវត្តអោយបានម៉ឺងម៉ាត់ និង ទទួលបានលទ្ធផលល្អប្រសើរនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលជាមួយមូលនិធិរូបិយវត្ថុ «IMF» រាជរដ្ឋាភិបាល សូមសំណូមពរចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង ប្រធានគ្រប់ស្ថាប័នកណ្តាល ឯកឧត្តមប្រតិភូតំណាងរាជរដ្ឋាភិបាល និង ឯកឧត្តមអភិបាលគ្រប់ខេត្ត–ក្រុងថា : នៅដើមខែ មេសា ឆ្នាំ ១៩៩៥ នេះ ក្រសួង–ស្ថាប័ន និង ខេត្ត–ក្រុងពាក់ព័ន្ធទាំងអស់ត្រូវត្រៀម និង ផ្តល់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវទិន្នន័យ និង តួលេខមួយចំនួនតាមខ្លឹមសារ និង កាលបរិច្ឆេទដូចតទៅ :

១–តារាងឧបសម្ព័ន្ធទី ១ និង ទី ២ ដូចមានជូនភ្ជាប់មកជាមួយនេះ ជារៀងរាល់ខែចាប់ពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៥ នេះតទៅ ។ ដោយឡែកចំពោះរបាយការណ៍លើកទី ១ នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៥ ត្រូវបញ្ចូលបន្ថែមនូវតួលេខដែលមានតាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ មកដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៥ ។

២–និតិវិធីលំអិតក្នុងការប្រមែប្រមូល ទិន្នន័យ និង តួលេខជាក់ស្តែង ។

អាស្រ័យហេតុនេះ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង ប្រធានគ្រប់ស្ថាប័នកណ្តាល ឯកឧត្តមប្រតិភូតំណាងរាជរដ្ឋាភិបាល និង ឯកឧត្តមអភិបាលគ្រប់ខេត្ត–ក្រុង ទទួលអនុវត្តតាមខ្លឹមសារដូចបានជំរាបជូនខាងលើអោយបានប្រសិទ្ធភាពល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១

ព្រះហស្តលេខានិង ត្រា

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

ពត៌មានស្តីពីអាជីវកម្មឈើ

* * *

ឈ្មោះក្រសួង ឬស្ថាប័នរដ្ឋដែលជូនដំណឹង :

របាយការណ៍ ប្រចាំខែ :

កាលបរិច្ឆេទ របាយការណ៍ :

	បរិមាណ (ម៣)	ថ្លៃ ($/ម៣)	តំលៃ ($)
១-ឈើហ៊ុប គរទុកនៅចុងខែ របាយការណ៍			
២-ឈើហ៊ុប បានលក់ក្នុងស្រុកនៅក្នុងខែ របាយការណ៍			
៣-ឈើហ៊ុប បាននាំចេញនៅក្នុងខែ របាយការណ៍			
៤-ឈើហ៊ុប ដែលនឹងត្រូវលក់ក្នុងស្រុកដល់ដាច់ឆ្នាំ			
៥-ឈើហ៊ុប ដែលនឹងត្រូវនាំចេញដល់ដាច់ឆ្នាំ			
៦-ឈើអារ គរទុកនៅចុងខែ របាយការណ៍			
៧-ឈើអារ បានលក់ក្នុងស្រុកនៅក្នុងខែ របាយការណ៍			
៨-ឈើអារ បាននាំចេញនៅក្នុងខែ របាយការណ៍			
៩-ឈើអារ ដែលនឹងត្រូវលក់ក្នុងស្រុកដល់ដាច់ឆ្នាំ			
១០-ឈើអារ ដែលនឹងត្រូវនាំចេញដល់ដាច់ឆ្នាំ			

ពត៌មានស្តីពី កិច្ចសន្យារបស់រាជរដ្ឋាភិបាល

ឈ្មោះក្រសួង ឬស្ថាប័នរដ្ឋដែលជូនដំណឹង :

របាយការណ៍ប្រចាំខែ :

កាលបរិច្ឆេទរបាយការណ៍ :

១-ឈ្មោះភាគីនៃកិច្ចសន្យា	:
២-កាលបរិច្ឆេទនៃកិច្ចសន្យា	:
៣-ប្រតិទិននៃការទទួលកំរៃ និង ថ្លៃឈ្នួល (ខែ/ឆ្នាំ និងបរិមាណជា $)	:
៤-បរិមាណកំរៃ និងថ្លៃឈ្នួលប្រចាំខែ (គិតជា $)	:
បរិមាណជាសាច់ប្រាក់	:
បរិមាណក្នុងធនាគារ	:
ឈ្មោះ និង ទីតាំងរបស់ធនាគារ	:
ឈ្មោះម្ចាស់គណនេយ្យ	:
លេខគណនេយ្យ	:
បរិមាណមានជាទ្រព្យរាយផ្សេង ៗ (សូមបញ្ជាក់)	:
បរិមាណដែលបានបង់អោយបុគ្គល ឬ ភ្នាក់ងារផ្សេង ៗ (សូមបញ្ជាក់)	:
បរិមាណដែលបានចំណាយលើទំនិញ និង សេវាផ្សេង ៗ (សូមបញ្ជាក់)	:
បរិមាណដែលបានបញ្ជូនទៅរតនាគារ	

ជាសាច់ប្រាក់	:
បង្វិលតាមរយៈធនាគារ	:
ផ្សេង ៗ (សូមបញ្ជាក់)	:

* * *

II .ការងារបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១០២ ប្រក.សហវ.ថ

ស្ដីអំពីការបង្វែរឥណទាន

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្ដីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ៨៨៤ អយក.ផក.ហវ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៥ និង លេខ ៩៤៩ អយក.ផក.ហវ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងអប់រំយុវជន និង កីឡា ផ្នែកអប់រំ សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
១១	០១	១៤	០២	ការបង្វែរពីជំពូក ១១ ចំណាយបោះពុម្ពសៀវភៅសិក្សា	៥០០.០០០,០០		៣៣.០០០,០០ ៣៣.០០០,០០	៤៦៧.០០០,០០
១១	០១	០៧	០១	ផលប្រយោជន៍ជំពូក ១១ ការថែទាំ និង ដំណើរការ «សំភារៈរថយន្ត»	៥៥.០០០,០០	៣៣.០០០,០០ ៣៣.០០០,០០		៨៨.០០០,០០
៣១	០១	០១	៩៩	ការបង្វែរពីជំពូក ៣១ ចំណាយការងារសង្គមកិច្ចផ្សេងៗ	៣៦.០០០,០០		២១.០០០,០០ ២១.០០០,០០	១៥.០០០,០០
៣១	០១	០១	១០	ផលប្រយោជន៍ជំពូក ៣១ ឧបត្ថម្ភនិវត្តជន	៥.០០០,០០	២១.០០០,០០ ២១.០០០,០០		២៦.០០០,០០

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

នាយ ថន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១០៨ ប្រ.សហវ.ហ

ស្តីពីការបង្វែរថវិកាដែលក្រុមហ៊ុនអាកាសចរកម្ពុជា
ជំពាក់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាដល់ដំណាច់
ខែ មករា ឆ្នាំ ១៩៩៤ ចំនួន ៥៩០.១៨៥,៣៣
ដុល្លារអាមេរិក និង ១.៥៤២.៩៦៦.១៦១រ00

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធរៀបចំហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

- បានឃើញអនុក្រឹត្យលេខ ០៩ អ.ន.ក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសលេខ ០០៦ ប្រ.សហវ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- បានឃើញលិខិតជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១២១៦ សជណ.ផក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីករណីសំណើជួយអន្តរាគមន៍ នូវប្រការជំពាក់របស់ក្រុមហ៊ុនអាកាសចរស៊ីវិលកម្ពុជា ដល់ដំណាច់ខែ មករា ឆ្នាំ ១៩៩៤
- តាមសំណើរបស់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាលេខ ១១២២ អអសពក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រុមហ៊ុនអាកាសចរភូមិន្ទកម្ពុជាលេខ ១៦ ល.ស ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីសំណើសុំជួយធ្វើអន្តរាគមន៍ ទារប្រាក់ជំពាក់ចំពោះអង្គភាព ក្រសួង មន្ទីរ ដែលជំពាក់បំណុល ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយជំរះចោលចេញពីបញ្ជីបំណុលរបស់អាកាសចរភូមិន្ទកម្ពុជា នូវតួលេខបំណុលរបស់អង្គភាពទាំងប្រាំ (០៥) ដែលពុំមានឈ្មោះចែងក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ហើយចាត់ទុកជាបំណុលរបស់រដ្ឋ និង ត្រូវទូទាត់ជាចាំបាច់ដោយថវិការដ្ឋ ចំនួនទឹកប្រាក់សរុប ១.៤៣៣.៧២២.៣៩៥៛ ក្នុងនោះ ÷

–ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ (បំណុលឆ្នាំ ១៩៩២)	:	៥៩.៦៩២.០០០៛០០
–គណៈកម្មាធិការត្រួតពិនិត្យ (បំណុលឆ្នាំ ១៩៩២)	:	៧៤៨.៨០០៛០០
–គណៈកម្មាធិការកណ្តាល	:	៩១១.៨៦៧.៥៩៥៛០០
–គណៈកម្មធិការរៀបចំបុណ្យជាតិ (បំណុលឆ្នាំ ១៩៩៣)	:	៤៣៩.៧៥៤.០០០៛០០
–គណៈចាត់តាំងមជ្ឈឹម (បំណុលឆ្នាំ ១៩៩៣)	:	២១.៦៦០.០០០៛០០

ប្រការ ២ : បំណុលជំរះបញ្ជីមានចំនួនទឹកប្រាក់ដូចក្នុងប្រការ ១ ចាត់ទុកថា អាកាសចរភូមិន្ទកម្ពុជា បានកាត់ផាត់សងបំណុលជូនអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាស្មើនឹងទឹកប្រាក់ ១.៤៣៣.៧២២.៣៩៥៛០០ ។

ប្រការ ៣ : អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ចាំបាច់ត្រូវលុបចេញពីបញ្ជីបំណុលត្រូវទាររបស់ខ្លួន តាមចំនួនតួលេខដូចក្នុងប្រការ ១ ។

ប្រការ ៤ : អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា និង អាកាសចរភូមិន្ទកម្ពុជា ព្រមទាំងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តអោយបានសំរេចតាមសេចក្តីប្រកាស ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១១២ ប្រក.សហវ.៩

ស្តីអំពីការបង្វែរឥណទាន

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃ ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥

- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូកប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តា ក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ១១៦៩ អយក.ផក.ហវ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងអប់រំយុវជន និង កីឡា ផ្នែកយុវជន និង កីឡា សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			30.000	
11	01	01	02	ការរៀបចំ និងថែទាំ	94.500	-	30.000	64.500
				ផលប្រយោជន៍ជំពូក១១		30.000		
11	01	08	01	សៅហ៊ុយទទួលភ្ញៀវបរទេស	10.000	30.000	-	40.000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ០០៩ សសរ.សហវ.ខ

ស្តីពីការផាកពិន័យ និង ការកសាងសំណុំរឿងបញ្ជូនទៅតុលាការ

អំពីករណីរត់ពន្ធល្មើសច្បាប់របស់ក្រុមហ៊ុន គីម ឃាង់ និងក្រុមហ៊ុន

VASAN SHIPPIG & TRADING PTE ,LTD ម្ចាស់នាវា GENA

* * *

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃ គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និង នាំចូលដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញលិខិតរបស់ ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៥៤២ សជណ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ក/–ធ្វើការផាកពិន័យក្រុមហ៊ុន **គីម ឃាង់** ព្រមទាំងតម្រូវអោយបង់ពន្ធនាំចូល និង អាករប្រើប្រាស់ ក្នុងទឹកប្រាក់សរុប ចំនួន ២.៤៧៣.០០០,០០ «ពីរលានបួនសែន ចិតសិបបីពាន់» ដុល្លារអាមេរិក ចំពោះមុខទំនិញដែលជាវត្ថុតាង ក្នុងពេល

ប្រព្រឹត្ត បទល្មើសរត់ពន្ធជាក់ស្តែង តាមនាវា GENA នៅក្រុងព្រះសីហនុមាន ដូចតទៅ ÷

១–រថយន្តចង្កូតឆ្វេងថ្មីម៉ាកហុងដា «១៩៩៤» ចំនួន ០៦ គ្រឿង
២–ម៉ាស៊ីនភ្លើងថ្មី ចំនួន ៥៦ គ្រឿង
៣–បារី ៥៥៥ និង បារីផ្សេងទៀត ចំនួន ៦.២១៨ ប៊ិច
៤–សំភារៈផ្សាយពាណិជ្ជកម្ម ចំនួន ៩៣ កេស ។

ខ/ធ្វើការផាកពិន័យចំពោះក្រុមហ៊ុន VASAN SHIPPING & TRADING PTE.,LTD ដែលជាម្ចាស់មធ្យោបាយនាវាប្រព្រឹត្តបទល្មើស GENA ព្រមទាំងនាវិក ១០ នាក់ ក្នុងទឹកប្រាក់ ចំនួន ១.៥០០.០០០,០០ «មួយលានប្រាំសែន» ដុល្លារអាមេរិក ។

ប្រការ ២: លោកនាយកទីចាត់ការគយនិងរដ្ឋាករ ត្រូវរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីរឹបអូសរថយន្តចង្កូតស្តាំ ចំនួន ២៧ គ្រឿង ។

ប្រការ ៣ : ក/ក្រុមហ៊ុន **គីម ហាប់** ត្រូវបង់ប្រាក់ ចំនួន ២.៤៧៣.០០០,០០ «ពីរលានបួនសែនប្រាំពីរម៉ឺនបីពាន់» ដុល្លារអាមេរិក ដូចបានកំណត់ក្នុងប្រការ ១ ចំណុច ក ខាងលើ ចូលក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅធនាគារជាតិក្នុងរយៈពេល ១៥ ថ្ងៃ ចាប់ពីថ្ងៃចុះហត្ថលេខា លើសេចក្តីសំរេចនេះ ។

ខ/ក្រុមហ៊ុន VASAN SHIPPING & TRADING PTE., LTD ត្រូវបង់ប្រាក់ ចំនួន ១.៥០០.០០០,០០ «មួយលានប្រាំសែន» ដុល្លារអាមេរិក ដូចបានកំណត់ក្នុងប្រការ ១ ចំណុច ក ខាងលើ ចូលក្នុងគណនីរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅធនាគារជាតិក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃចុះហត្ថលេខាលើសេចក្តីសំរេចនេះ ។

ប្រការ ៤ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាស លេខ ៣៥៧ ឧក.ប្រក ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១: អនុញ្ញាតអោយអ្នកស្រី **តែង ខ្មៀន** ជាប្រធានរោងម៉ាស៊ីនកិនស្រូវកំលាំង ៣៧ សេះ ដែលមានទីតាំងនៅ ភូមិប្រឡាយលួងលើ ឃុំឫស្សីក្រោក ស្រុក មង្គលបូរី ខេត្ត បាត់ដំបង ផ្ទេរ ភារកិច្ចគ្រប់គ្រងជូនលោក **យ៉ាំ ម៉ិនសុខ** វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **យ៉ាំ ម៉ិនសុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០០៦៨៥៧ ប.ជ ចុះថ្ងៃទី ០១-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ១៣ ភូមិគោកស្វាយ ឃុំ ឫស្សីក្រោក ស្រុក មង្គលបូរី ខេត្តបន្ទាយមានជ័យ ជាប្រធាន រោងម៉ាស៊ីនកិនស្រូវ ។

ប្រការ ៣ : លោក **យ៉ាំ ម៉ិនសុខ** ត្រូវចាប់ផ្តើមដំណើរផលិតកម្ម-អាជីវកម្ម លើទីតាំងដែល បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៤ : ប្រកាសលេខ ៣៥៨ ឧក.ប្រក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជា មោឃៈ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាស លេខ ៣៥៨ ឧក.ប្រក ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **គង់ សាយហួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្ត សញ្ញាណប័ណ្ណលេខ ៣៥១៥៤៣ ភ.ព ចុះថ្ងៃទី ០៦-១០-៩៣ អាស័យដ្ឋាន

បច្ចុប្បន្នភូមិទំពលោះ សង្កាត់ ព្រៃវែង ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញបើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **គង់ សាយហួយ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយជានា នូវ ទិន្នផលអង្ករលេខ ១ អោយបាន យ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន មានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាស លេខ ៣៥៩ ផក.ប្រក ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **ឈឹម សាក់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១០០១៩៧ ព.ស ចុះថ្ងៃទី ២០–៨–៩០ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ភូមិត្រពាំងជង ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិសាត់ បើកដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ១២០ សេះ នៅក្នុងទីតាំង ក្រុមទី ២ភូមិកោះស្វាយ ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិសាត់ ។

ប្រការ ២ : លោក **ឈឹម សាក់** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយជានានូវ ទិន្នផលអង្ករលេខ ១ អោយបាន យ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៣៦០ ផក.ប្រក ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **ញ៉ឹក ឌុត្ថី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០១៧៧១១ ប.ប ចុះថ្ងៃ

១១-៣-៨៦ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២៥ ភូមិចំការសំរោង ២ សង្កាត់ចំការសំរោង ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង បើក ដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីន កំលាំង ៨០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ញ៉ុក ឧត្តម** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានា នូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន មានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៣៦១ ឧក.ប្រក ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឈៀម រាស់** ជនជាតិខ្មែរ សញ្ញាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណលេខ ១៧២២៣១ ប.ប ចុះថ្ងៃទី ៣១-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្នក្រុម ទី ២ ភូមិគរ ឃុំស្ទឹង ស្រុក បាណន់ ខេត្ត បាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកំលាំង ៣១ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឈៀម រាស់** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានា នូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមាន មានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

